# ទឹកចិត្តកូនម៉ែ

កូនបានអានលិខិត ដែលចេញពីដួងចិត្ត អ្នកម្តាយមានគុណ
អ្នកម្តាយរៀបរាប់ ទុក្ខសោកទារុណ្ឌ ដែលម៉ែរែកពន់
ព្រោះបុត្រពិសី ។

ពាក្យពេចន៍សារស័ព្ទ ដែលម៉ែបានប្រាប់ សុទ្ធតែមានន័យ
ធ្វើអោយចិត្តកូន ភ្លឺឡើងដូចថ្ងៃ ដឹងចិត្តម៉ែថ្លៃ
ថាធំប៉ុណ្ណា ។

ដួងចិត្តអ្នកម៉ែ ទោះភ្នំព្រះសុមេរុ៍ ធំខ្ពស់ម្តេចម្តា
មិនអាចប្រៀបផ្ទឹម ឬយកឧបមា និងចិត្តមាតា
របស់កូនបានទេ ។

ទឹកចិត្តអ្នកម្តាយ ទោះខ្សាច់ទាំងឡាយ ក្នុងសាគរ-ទន្លេ
មិនអាចត្រារាប់ ប្រៀបធៀបគ្មាន់គ្ហេ នឹងចិត្តរិះរេ
របស់អ្នកម្តាយថ្លៃ ។

ចិត្តម៉ែមានគុណ ធ្ងន់អើយសែនធ្ងន់ ទោះបីផែនដី
ក៏ធ្ងន់មិនដូច ទឹកចិត្តម្តាយថ្លៃ ធ្ងន់ហួសឧបមេយ្យ
នឹងវត្ថុក្នុងលោក ។

ម៉ែចិញ្ចឹមកូន ម៉ែក្រាបម៉ែលូន ទាំងក្តីទុក្ខសោក
មិនថាភ្លៀងផ្គរ ឬម៉ែមានរោគ ក៏ម៉ែស៊ូក្រោក
ដើម្បីកូនស្ងួន ។

ម៉ែបានពីគេ មិនហ៊ានប្រើទេ បច្ច័យទាំងបួន
ម៉ែសុខចិត្តវេច កាត់ថ្សិចផ្ញើកូន នៅក្រុងរង្គូន
ប្រទេសភូមា ។

ម៉ែផ្ញើមកសព្វ មានប្រហុកខ្ជប់ ព្រមទាំងផ្អកត្រា
នៃប៉ូវនិងសៀង ម៉ែដាក់ផ្សេងគ្នា ទុកបានយូរយា
សំរាប់ឆាន់ក្រោយ ។

ឱ៎ះ ឱ ! អ្នកម៉ែ ម៉ែខំមើលថែ កូនគ្រប់ជ្រុងជ្រោយ
ទោះម៉ែនៅឆ្ងាយ ក៏មិនបណ្តោយ អោយកូនសោកសោយ
នូវក្តីវេទនា ។

ឱះ ឱ ! អ្នកម៉ែ ម៉ែបានផ្ដាំផ្ញើ ដល់កូនរាល់គ្នា
អោយចេះអត់ឱន លំទោនរកគ្នា អភិរក្សសាមគ្គា
ជាធមិនាំសុខ ។

អោយកូនប្រឹងរៀន វិជ្ជាជាស្ពាន សំរាប់ឆ្លងទុក្ខ
វាលវដ្ដសង្សារ យាត្រាទៅមុខ ដល់ទីផុតទុក្ខ
គឺព្រះនិព្វាន ។

ឱ ! អ្នកម្ដាយថ្លៃ កូនប្រុសពិសី សូមសច្ចាប្រណិធាន
ចំពោះមុខម៉ែ ថានឹងខំរៀន តាមដំបូន្មាន
របស់មាតា ។

ទោះគ្មានអ្វីឆាន់ អោយបានគ្រប់គ្រាន់ យ៉ាងដូចម្ដេចម្ដា
កូនម៉ែស៊ូទ្រាំ តស៊ូសិក្សា ចាប់យកបញ្ញា
បំពេញចិត្តម៉ែ ។

មិនតែប៉ុណ្ណោះ កូនម៉ែទាំងអស់ នឹងជួយមើលថែ
រក្សាគ្រប់គ្រង បងប្អូនពុកម៉ែ ជាជនជាតិខ្មែរ
អោយដើរផ្លូវត្រូវ ។

កូននឹងរក្សា ព្រះពុទ្ធសាសនា អោយគង់វង្សនៅ
ក្នុងដែនកម្ពុជា តកូនតចៅ ដើម្បីជាផ្លូវ
សុភមង្គល ។

អ្នកម្ដាយមានគុណ អ្នកធ្វើការធ្ងន់ ហួសថាមពល
ព្រោះតែរូបកូន អោយម៉ែរវល់ ស្ទើរតែដាច់ខ្យល់
ចាកចោលលោកិយ ។

ជាទីអវសាន កូនម៉ែគ្រប់ប្រាណ សូមនូវអភ័យ
សូមម៉ែអត់ទោស សន្ដោសប្រណី ដល់បុត្រពិសី
នៅភូមាផង ។

ឱ អ្នកមាតា កូនគ្រប់អាត្មា អរគុណកន្លង
ចំពោះម៉ែថ្លៃ ដែលបានចំលង រូបកូនប្អូនបង
អោយផុតទុក្ខា ។

គុណម៉ែធំណាស់ កូនប្រុសចាំច្បាស់ លុះថ្ងៃមរណា
កូននឹងតបវិញ បើមានវាសនា រស់លើលោកា
បានយូរអង្វែង ។

ពេលនេះកូនប្រុស របស់ម៉ែទាំងអស់ នាំគ្នាថ្លាថ្លែង
ជូនពរអ្នកម៉ែ សូមមានអាយុវែង សម្បុរថ្លាឈ្វេង
ដូចបញ្ចពិធ ។

សូមអោយអ្នកម្តាយ មានសេចក្តីសុខកាយ ព្រមទាំងផ្លូវចិត្ត
កំលាំងពលំ ទាំងកាយទាំងចិត្ត នៅមាំមួនពិត
ដូចដីវីសា ។

សូមអោយអ្នកម្តាយ រីករាយសប្បាយ តែនិងធម៌អាថិ
មូលកូនមូលចៅ មូលញាតិកា មូលមិត្តសាសនា
ទាំងប្រុសទាំងស្រី ។

បើម៉ែទៅណា សូមពួកទេវតា រក្សាអោយជ័យ
កំចាត់ឧបសគ្គ គ្រោះថ្នាក់ចង្រៃ បាបកាឡកិណី
ចេញឆ្ងាយកាយា ។

នៅទីបញ្ចប់ សូមម៉ែសំណប់ ឆ្លងផុតទុក្ខា
ដល់ព្រះនិព្វាន ជាឋានថ្លៃថ្លា សមដូចប្រាថ្នា
រៀងរហូតទៅ ។

ចិត្តកូនគិតមាត់កូនវាចា ដៃកូនស្រវាចាប់ប៊ិចសៀវភៅ
សរសេររឿងពិតដែលមាននិត្យនៅ កប់ក្នុងក្រអៅរបស់កូនម៉ែ ។
ខុសឬត្រូវយ៉ាងម្តេចម្តា សូមអ្នកមាតាករុណាជួយកែ
និងអត់ទោសកូនដែលឃ្លាតចាកខ្មែរ រស់នៅស្រុកគេកំព្រាឯកា ។
គំនិតកូនតិចត្បិតកូននៅខ្ចី ប្រើប្រាស់សំដីសារសព្ទវាចា
បង្ហាញទឹកចិត្តកូនគ្រប់រូបា ចំពោះមាតានៅកម្ពុជា ។
សូមចប់ប៉ុណ្ណេះស្លេះវាចា កូនគ្រប់អាត្មាសូមលាតលា
អ្នកម្តាយមានគុណនៅកម្ពុជា ពីប្រទេសភូមាដ៏សែនឆ្ងាយ ។

ភូមាថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៨

និពន្ធដោយភិក្ខុ **ស៊ុយ សុវណ្ណ**

បរិញ្ញាកសមាគមសមណនិស្សិតខ្មែរប្រទេសភូមា

មកពីវត្តបឹងកុក កំពង់ចាម